Received by NSD/FARA Registration Unit 08/19/2025 2:54:27 PM

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

# សេចក្តីជូនព័ត៌មាន

## ស្តីពីដំណើរទស្សនកិច្ចរបស់ក្រុមអ្នកជំនាញជាន់ខ្ពស់មកពីសារមន្ទីរជាតិសិល្បៈអាស៊ី ក្នុងក្របខ័ណ្ឌអនុស្សរណៈនៃការយោគយល់គ្នារវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងស្ថាប័នស្មីតសូនៀន ( Smithsonian Institution)

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ មានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា ក្រុមអ្នកជំនាញជាន់ខ្ពស់មកពីសារមន្ទីរជាតិសិល្បៈអាស៊ីនៃវិទ្យាស្ថានស្មីតសូនៀន នៅទីក្រុងវ៉ាស៊ីនតោនឌីស៊ី សហរដ្ឋអាមេរិក បានមកបំពេញទស្សនកិច្ចសិក្សា រយៈពេលមួយសប្តាហ៍នៅកម្ពុជា នៅដើមខែមេសា ឆ្នាំ២០២៥។ សមាសភាពគណៈប្រតិភូរួមមានអ្នកជំនាញផ្នែក៖ គ្រប់គ្រងសមុច្ច័យ ការតាំងពិព័រណ៍ការស្រាវជ្រាវឯកសារ និងការអភិរក្ស។ ដំណើរទស្សនកិច្ចនេះគឺជាជំហានដ៏សំខាន់មួយ ក្នុងការអនុវត្តគោលបំណងរួមដែលបានគូសបញ្ជាក់នៅក្នុងអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ២០២៣ រវាងក្រសួងវប្បធម៌និងវិចិត្រសិល្បៈ និងស្ថាប័នស្មីតសូនៀន ដើម្បីពង្រីកការផ្លាស់ប្តូរវប្បធម៌ លើកកម្ពស់ការយល់ដឹងអំពីសិល្បៈវប្បធម៌ និងការពង្រឹងជំនាញវិជ្ជាជីវៈសារមន្ទីរ ជាពិសេសក្នុងវិស័យស្រាវជ្រាវប្រភពដើម ការប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់ និងការបញ្ជូនត្រឡប់មកវិញនូវសម្បត្តិវប្បធម៌។ កិច្ចសហប្រតិបត្តិការនេះក៏ឆ្លើយតបទៅនឹងយុទ្ធនាការប្រកបដោយជោគជ័យរបស់កម្ពុជា ក្នុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ ក្នុងការទាមទារបញ្ជូនត្រឡប់មកកម្ពុជាវិញនូវសម្បត្តិវប្បធម៌ជាតិរាប់រយពីប្រទេសនានា រួមទាំងស្ថាប័ន និងអ្នកប្រមូលសមុច្ច័យឯកជននានានៅសហរដ្ឋអាមេរិក។

គោលដៅចម្បងនៃដំណើរទស្សនកិច្ចនេះ គឺដើម្បីបន្តកិច្ចពិភាក្សាអំពីផែនការរៀបចំតាំងពិព័រណ៍លំដាប់ពិភពលោក ផ្តោតលើរាជធានីបុរាណកោះកេរ ដែលត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូនាឆ្នាំ២០២៣ ហើយគ្រោងនឹងសម្ពោធនៅកម្ពុជា នៅឆ្នាំ២០៣០ និងនៅសារមន្ទីរជាតិសិល្បៈអាស៊ី ទីក្រុងវ៉ាស៊ីនតោនឌីស៊ី នៅឆ្នាំ២០៣១។ គណៈប្រតិភូបានទៅទស្សនាសារមន្ទីរសំខាន់ៗមួយចំនួននៅរាជធានីភ្នំពេញ និងនៅខេត្តសៀមរាប ក៏ដូចជាទីតាំងប្រាសាទបុរាណមួយចំនួនផងដែរ ព្រមទាំងបានជួបជាមួយអ្នកជំនាញជាច្រើនរូបមកពីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សារមន្ទីរជាតិកម្ពុជា អាជ្ញាធរជាតិសំបូរព្រៃគុក អាជ្ញាធរជាតិអប្សរា អាជ្ញាធរជាតិព្រះវិហារ និងក្រុមហ៊ុន Edenbridge Asia។

លោកជំទាវបណ្ឌិតសភាចារ្យ ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានមានប្រសាសន៍ថា៖ «យើងសូមស្វាគមន៍ចំពោះកិច្ចសហប្រតិបត្តិការរវាងប្រទេសយើងទាំងពីរ ប្រកបដោយភាតរភាព និងមានសេចក្តីរីករាយសហការជាមួយស្ថាប័នស្មីតសូនៀន ដែលជាស្ថាប័នឈានមុខគេលើពិភពលោកក្នុងវិស័យសារមន្ទីរ»។ ទន្ទឹមនេះ លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី បានថ្លែងអំណរគុណ និងកោតសរសើរដោយស្មោះចំពោះកិច្ចខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានជួយសម្របសម្រួលដំណើរទស្សនកិច្ចរបស់គណៈប្រតិភូ ជាពិសេសសូមថ្លែងអំណរគុណចំពោះស្ថានទូតសហរដ្ឋអាមេរិកនៅភ្នំពេញ និងក្រុមការងារបុរាណវិទ្យា និងស្រាវជ្រាវរបស់ក្រសួង។ លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី ក៏បានថ្លែងអំណរគុណជាពិសេសចំពោះលោក Bradley J. Gordon និងក្រុមការងាររបស់ក្រុមហ៊ុន Edenbridge Asia ដែលបានលះបង់កម្លាំងកាយចិត្ត អស់ជាច្រើនឆ្នាំ ចូលរួមគាំទ្រនិងសហការជាមួយ



Received by NSD/FARA Registration Unit 08/19/2025 2:54:27 PM

Received by NSD/FARA Registration Unit 08/19/2025 2:54:29 PM

មន្ត្រីជំនាញរបស់ក្រសួង ក្នុងការចរចាទាមទារសម្បត្តិវប្បធម៌ខ្មែរត្រឡប់មកកម្ពុជាវិញ ព្រមទាំងបានផ្តួចផ្តើមគំនិតនៃកិច្ចសហប្រតិបត្តិការនេះ។

លោកជំទាវបណ្ឌិតសភាចារ្យរដ្ឋមន្ត្រីបានបន្ថែមថា «យើងទទួលស្គាល់នូវភាពស្រស់ស្អាត និងភាពអស្ចារ្យនៃរាជធានីបុរាណកោះកេរ។យើងមានសេចក្តីរីករាយក្នុងការចាប់ផ្តើមរៀបចំផែនការតាំងពិព័រណ៍លំដាប់ពិភពលោក ស្តីពីកោះកេរ និងក៏ជាឱកាសបង្ហាញពីរតនសម្បត្តិជាតិរបស់យើងដែលបានវិលត្រឡប់មកកម្ពុជាវិញ ដែលនឹងនាំមកនូវការទាក់ទាញចំណាប់អារម្មណ៍ និងការយកចិត្តទុកដាក់ចំពោះប្រវត្តិសាស្ត្រដ៏សម្បូរបែបរបស់កម្ពុជា»។

ថ្ងៃសុក្រ ១៣រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៥

Received by NSD/FARA Registration Unit 08/19/2025 2:54:29 PM